ផ្ញើសំបុត្រទៅអ្នកបើការឆ្លើយតបអាចមានការយឺតយ៉ាវ ។ ក្នុងករណីកម្រខ្លះ យើងអាចនឹងបដិសេធការស្នើសុំពិនិត្យ និងថតចំលងកំណត់ត្រាព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ។ ក្នុងករណីនេះ អ្នកនឹងទទួលសំបុត្រពន្យល់ពីហេតុផល និងព័ត៌មានពីការតវ៉ាទៅប្រធានស្ថាប័ន (ឬរដ្ឋមន្ត្រីក្រសួង) សុខាភិបាល និងសេវាកម្មពលរដ្ឋ ប្រសិនបើអ្នកចង់ធ្វើការតវ៉ា ។

- ទទួលប្រវត្តិនៃការបញ្ចេញព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ក្នុងរយៈពេល6ឆ្នាំកន្លងមកនេះ ដែលធ្វើអោយអ្នកដឹងពីហេតុផលនៃការចែកចាយព័ត៌មាន និងស្ថាប័នណាខ្លះដែលបានទទួលព័ត៌មានរបស់អ្នក ។ ប្រវត្តិនៃការបញ្ចេញព័ត៌មាននឹងមិនរួមមានប្រវត្តិពីការព្យាបាល ការបង់ប្រាក់ ប្រតិបត្តិការនៃការថែរក្សាសុខភាព ឬការបញ្ចេញព័ត៌មាននានាឡើយ ។ យើងនឹងផ្តល់ជូននូវប្រវត្តិនៃការបញ្ចេញព័ត៌មានដោយមិនគិតប្រាក់មួយឆ្នាំម្តង ប៉ុន្តែអ្នកត្រូវបង់ប្រាក់ប្រសិនបើអ្នកស្នើសុំលើសពីមួយដងក្នុងមួយឆ្នាំ ។
- ជ្រើសរើសរបៀបនៃការផ្ញើព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ។
- បញ្ចប់ការអនុញ្ញាតិអោយប្រើប្រាស់ ឬបញ្ចេញព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក លើកលែងតែចំពោះសកម្មភាពណាដែលបានអនុវត្តរួចហើយ ។
- ទទួលការជូនដំណឹងភ្លាមៗនៅពេលមានការបែកធ្លាយព័ត៌មានសម្ងាត់ផ្នែកវេជ្ជសាស្ត្ររបស់អ្នក ។

**ការទទួលខុសត្រូវរបស់យើង៖**
**ស្ថាប័ននេះតម្រូវអោយ៖**

- ថែរក្សាព័ត៌មានផ្នែកវេជ្ជសាស្ត្ររបស់អ្នក
- ប្រសិនបើចាំបាច់ត្រូវប្រើប្រាស់ឬបញ្ចេញព័ត៌មាន ត្រូវបញ្ចេញក្នុងកំរិតតិចបំផុត
- ផ្តល់ការជូនដំណឹងដល់អ្នកពីសិទ្ធិ និងការអនុវត្តឯកជនភាព ចំពោះព័ត៌មានរបស់អ្នកដែលយើងបានទទួល និងរក្សាទុក ។
- គោរពទៅតាមលក្ខខណ្ឌក្នុងសេចក្តីជូនដំណឹងនេះ
- ផ្តល់ដំណឹងដល់អ្នកនៅពេលយើងមិនអាចយល់ព្រមទៅនឹងការស្នើសុំដាក់កម្រិតពីការបញ្ចេញព័ត៌មានរបស់អ្នក។
- ផ្តល់ជូនទៅតាមមធ្យាបាយណាដែលសមស្របចំពោះអ្នក ពីការស្នើសុំការផ្តល់ព័ត៌មានសុខភាពរបស់អ្នក ។
- ផ្តល់ដំណឹងដល់អ្នក នៅពេលព័ត៌មានសុខភាពរបស់អ្នកបានបញ្ចេញដោយអចេតនា ។

**ស្ថាប័ននេះមិនអនុញ្ញាតិអោយ៖**

- លក់ព័ត៌មានរបស់អ្នកទៅក្រុមហ៊ុនសិក្សាទីផ្សារ ឬបុគ្គលណាឡើយ ។
- ពិភាក្សាជាមួយអ្នកពីផលិតផល ឬសេវាកម្មនានាដែលទាក់ទងនឹងសុខភាពរបស់អ្នក ដោយមិនមានការអនុញ្ញាតិពីអ្នកឡើយ បើយើងទទួលការបង់ប្រាក់ដោយផ្ទាល់ឬដោយប្រយោលចំពោះការពិភាក្សានេះ ។
- ប្រើប្រាស់ឬបញ្ចេញព័ត៌មានសុខភាពរបស់អ្នក ដោយមិនមានការអនុញ្ញាតិពីអ្នកលើកលែងតែក្រោមលក្ខខណ្ឌក្នុងសេចក្តីប្រកាសនេះ ។

យើងរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរការអនុវត្ត និងធ្វើលក្ខខណ្ឌថ្មីចំពោះព័ត៌មានសម្ងាត់ផ្នែកវេជ្ជសាស្ត្រដែលយើងថែរក្សា ។ ប្រសិនបើមានការផ្លាស់ប្តូរការអនុវត្ត យើងនឹងដាក់សេចក្តីប្រកាសថ្មីនៅក្នុងគេហទំព័រ longbeach.gov/health ។

### សំរាប់ព័ត៌មានបន្ថែម ឬរាយការណ៍ពីបញ្ហាណាមួយ៖

ប្រសិនបើអ្នកមានសំនួរ និងព័ត៌មានបន្ថែម ឬបើអ្នកគិតថាព័ត៌មានឯកជនភាពរបស់អ្នកមានការបំពាន ហើយអ្នកចង់ធ្វើការតវ៉ា សូមទាក់ទងទៅ៖

**មន្ត្រីអនុវត្តឯកជនភាព HIPAA របស់នាយកដ្ឋានសុខាភិបាលនៃសាលាក្រុងឡុងប៊ិច**

(562) 570-4330

**ឬ**

**ការិយាល័យសិទ្ធិប្រជាពលរដ្ឋរបស់សហរដ្ឋអាមេរិក**

(800) 368-1019

*មិនមានការតបតណាមួយឡើយ ក្នុងការដែលអ្នកធ្វើការតវ៉ា ។*

អ្នកអាចស្នើសុំឯកសាព័ត៌មាននេះក្នុងទំរង់ដ៏ទៃទៀតបាន ដោយធ្វើការស្នើសុំទៅមន្ត្រីអនុវត្តឯកជនភាព HIPAA នាយកដ្ឋានសុខាភិបាល និងសេវាកម្មពលរដ្ឋ នៃសាលាក្រុងឡុងប៊ិច ៖

**មន្ត្រីអនុវត្តឯកជនភាព HIPAA**
**(HIPAA Privacy Officer)**

City of Long Beach
Department of Health & Human Services
2525 Grand Avenue
Suite 280, Long Beach, CA 90815
(562) 570-4330

កាលបរិច្ឆេទចូលជាធរមាន: 04/2009 - បានកែប្រែ: 11/2015

# សេចក្តីប្រកាស អំពីការអនុវត្តឯកជនភាព

## ទីក្រុងឡុងប៊ិច នាយកដ្ឋានសុខាភិបាល និងសេវាកម្មពលរដ្ឋ

**សេចក្តីប្រកាសនេះ បង្ហាញអ្នកអំពីរបៀបប្រើប្រាស់ ផ្សព្វផ្សាយ និងការទទួលយកព័ត៌មាន។**

**សូមពិនិត្យអោយបានលំអិត ។**

CITY OF LONG BEACH

ព័ត៌មានសុខភាព (ឬព័ត៌មានផ្នែកវេជ្ជសាស្ត្រ) របស់អ្នកជាព័ត៌មានផ្ទាល់ខ្លួន និងត្រូវរក្សាជាការសម្ងាត់។ សាលាក្រុងឡងប៊ិច ប្តេជ្ញាការពារព័ត៌មានសុខភាពរបស់អ្នក។ យើងតម្រូវដោយច្បាប់របស់រដ្ឋបាលសហពន្ធ័ និងច្បាប់របស់រដ្ឋ ក្នុងការរក្សាការសម្ងាត់ព័ត៌មានសុខភាពរបស់អ្នកជំងឺ និង/ឬ អាចបញ្ចេញព័ត៌មាននេះបានតាមគោលការណ៍ច្បាប់ដ៏តឹងរឹងបំផុតតែប៉ុណ្ណោះ។ សេចក្តីប្រកាសពីការអនុវត្តព័ត៌មានជាឯកជននេះ ប្រាប់អ្នកអំពីបែប បទផ្នែកច្បាប់ដែលយើងអាចប្រើប្រាស់ និងចែករំលែកព័ត៌មានសុខភាពរបស់អ្នក។ យើងតម្រូវអោយផ្តល់ជូនលោកអ្នកនូវសេចក្តីប្រកាសនេះ ហើយយើងក៏តម្រូវអោយគោរពទៅតាមលក្ខន្តិកៈទាំងអស់នៅក្នុងសេចក្តីប្រកាសនេះដែលបានចូលជាធរមាន។

**ព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកអាចត្រូវបានប្រើប្រាស់ ឬបញ្ចេញដោយមិនចាំបាច់ទទួលការអនុញ្ញាតពីអ្នក ចំពោះករណីខាងក្រោម៖**

- **ការព្យាបាល៖** ព័ត៌មានដែលទទួលបានពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់ក្រុង (បុគ្គលិករដ្ឋ) នឹងត្រូវកត់ត្រាក្នុងប្រព័ន្ធកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក។ ព័ត៌មាននេះអាចត្រូវចែករំលែកទៅអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀត ដែលកំពុងព្យាបាលអ្នក ដើម្បីធានាថាអ្នកទទួលការព្យាបាល និងការវាយតម្លៃសុខភាពបានល្អត្រឹមត្រូវ។
- **ការបង់ប្រាក់៖** សាលាក្រុងអាចប្រើប្រាស់ព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ឬបង្ហាញវាទៅកាន់អ្នកផ្តល់សេវាធានារ៉ាប់រងសុខភាព ដើម្បីទូទាត់ប្រាក់ចំពោះសេវាសុខភាពដែលអ្នកបានទទួល។ ឧទាហរណ៍ យើងអាចត្រូវផ្តល់ព័ត៌មានពីការពិនិត្យសុខភាពនៅគ្លីនិក ឬការចាក់វ៉ាក់សាំង ដែលអ្នក ឬកូនរបស់អ្នកបានទទួល មុនពេលដែលគេនឹងបង់ប្រាក់សម្រាប់សេវាកម្មទាំងនោះ។ យើងក៏អាចប្រាប់ពួកគេ អំពីការព្យាបាលដែលអ្នកនឹងត្រូវទទួល ដើម្បីបានការយល់ព្រមជាមុន សម្រាប់ការព្យាបាល។
- **ប្រតិបត្តិការ ក្នុងការថែទាំសុខភាព៖** សាលាក្រុងអាចប្រើប្រាស់ ឬបង្ហាញព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកសម្រាប់អនុវត្តការថែទាំសុខភាព ដើម្បីប្រាកដថាសេវាកម្ម និងការថែទាំដែលផ្តល់ជូនអ្នកមានភាពសមស្រប និងមានគុណភាពខ្ពស់។ ឧទាហរណ៍ យើងអាចពិនិត្យមើលព័ត៌មានវេជ្ជសាស្ត្ររបស់បុគ្គលជាច្រើន ដើម្បីកែលម្អសេវាកម្មរបស់យើង។ យើងអាចចែករំលែកព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកទៅអ្នកផ្តល់សេវាផ្សេងទៀតដែលជាអ្នកគ្រប់គ្រងឯកសាររបស់អ្នកជំងឺ សម្រប សម្រួល ការថែទាំ ឬវាយតម្លៃផ្សេងទៀត។
- **សុខភាពសាធារណៈ៖** យោងតាមច្បាប់ យើងអាចបង្ហាញព័ត៌មានរបស់អ្នកដល់មន្ត្រីសាធារណៈ ឬមន្ត្រីផ្នែកច្បាប់ ដែលទទួលបន្ទុកការពារ ឬគ្រប់គ្រងជំងឺ ការរបួស ឬពិការភាព។
- **កំណត់ត្រាពីការព្យាបាលផ្នែកចិត្តសាស្ត្រ៖** ចំពោះស្ថាប័នដែលផ្តល់សេវាតវិយាវិទ្យា (ការព្យាបាលតវិយាបថ ឬការប្រព្រឹត្តរបស់បុគ្គល) និងថែរក្សាកំណត់ត្រានៃការព្យាបាលចិត្តសាស្ត្រ ក្រោមក្រឹត្យក្រមច្បាប់ HIPPA យើងនឹងសុំការអនុញ្ញាតពីអ្នកចំពោះការបង្ហាញពីកំណត់ត្រានៃការព្យាបាលចិត្តសាស្ត្រ និងការយកព័ត៌មានទាំងនោះទៅប្រើ ។ កំណត់ត្រានៃការព្យាបាលចិត្តសាស្ត្រ ជាកំណត់ត្រាជាក់លាក់មួយពីអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដែលធ្វើការកត់ត្រា ឬវិភាគព័ត៌មានទទួលបានពីការសន្ទនាក្នុងពេលប្រើសេវាផ្តល់យោបល់ និងដែលរក្សាទុកដោយឡែកពីកំណត់ត្រាសុខភាពទូទៅរបស់អ្នក
- **ការផ្សព្វផ្សាយ៖** យើងនឹងសុំការអនុញ្ញាតពីអ្នកមុននឹងប្រើប្រាស់ ឬបង្ហាញព័ត៌មានសុខភាពរបស់អ្នក ក្នុងគោលបំណងធ្វើការផ្សព្វផ្សាយ លើកលែងតែពេលមានការទំនាក់ទំនងផ្ទាល់ជាមួយអ្នក ឬមានការចែកសម្ភារៈផ្សព្វផ្សាយដែលមិនមានតំលៃជាទឹកប្រាក់ ដែលអ្នកយល់ព្រម ។
- **ការលក់ព័ត៌មាន៖** យើងនឹងសុំការអនុញ្ញាតពីអ្នកមុនពេលធ្វើការបញ្ចេញព័ត៌មានដែលមានលក្ខណៈជាការលក់ព័ត៌មានសុខភាព។
- **ការរៃអង្គាសប្រាក់៖** យើងនឹងសុំការអនុញ្ញាតពីអ្នក មុនពេលប្រើប្រាស់ ឬបង្ហាញព័ត៌មានសុខភាពរបស់អ្នក ក្រោមគោលបំណងនៃការរៃអង្គាសថវិកា។ អ្នកមានសិទ្ធបដិសេធ ហើយអ្នកក៏មានសិទ្ធិហាមយើងមិនឱ្យទាក់ទងអ្នកទាក់ទងនឹងសកម្មភាពរៃអង្គាសប្រាក់តទៅទៀត។

**ការប្រើប្រាស់និងបញ្ចេញព័ត៌មានផ្សេងទៀតដែលមិនចាំបាច់ការអនុញ្ញាតពីអ្នក ៖**

- **ការទំនាក់ទំនងអាជីវកម្ម៖** មានសេវាកម្មមួយចំនួនដែលយើងត្រូវប្រើប្រាស់អាជីវកម្មក្រៅស្ថាប័នតាមរយៈការចុះកិច្ចសន្យា ដូចជាបន្ទប់ពិសោធន៍វេជ្ជសាស្ត្រខាងក្រៅ និងសេវាថតចម្លងជាដើម។ ព័ត៌មានផ្នែកសុខភាពរបស់អ្នកអាចត្រូវបានបង្ហាញដល់អ្នកធ្វើអាជីវកម្មទាំងនោះ ដើម្បីពួកគេអាចផ្តល់សេវាកម្មចាំបាច់ដល់យើងខ្ញុំ ។ ក្នុងការការពារព័ត៌មានរបស់អ្នក យើងមានកិច្ចព្រមព្រៀងជាមួយអាជីវករទាំងនោះ ដែលតម្រូវឱ្យពួកគេការពារគ្រប់ព័ត៌មានសុខភាពរបស់អ្នកស្របតាមច្បាប់ និងស្តង់ដារនៃការអនុវត្តទាំងអស់នោះ។
- **ការជូនដំណឹង៖** យើងអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានដើម្បីជូនដំណឹង ឬជួយដល់ការជូនដំណឹងទៅដល់សមាជិកគ្រួសារ អ្នកតំណាងរបស់អ្នក ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវចំពោះការមើលថែទាំអ្នក ពីទីតាំងរបស់អ្នក ពីស្ថានភាពទូទៅ ឬការទទួលមរណៈភាព ។
- **ការស្រាវជ្រាវ៖** យើងអាចនឹងចែករំលែកព័ត៌មានរបស់អ្នកដល់ក្រុមអ្នកស្រាវជ្រាវនៅពេលដែលការស្រាវជ្រាវរបស់ពួកគេត្រូវអនុម័តដោយស្ថាប័នក្រុមប្រឹក្សាផ្នែកត្រួតពិនិត្យ (Institutional Review Board) ដែលពិនិត្យសំណើនេះ និងបង្កើតវិធានការដើម្បីធានាបាននូវភាពឯកជននៃព័ត៌មានផ្នែកសុខភាពរបស់អ្នក។
- **អ្នកគ្រប់គ្រងពិធីបុណ្យសព៖** យើងអាចចែករំលែកព័ត៌មានសុខភាពដល់អ្នកគ្រប់គ្រងពិធីបុណ្យសព ស្របតាមច្បាប់ដើម្បីពួកគេអាចអនុវត្តភារកិច្ចរបស់គេបាន។
- **រដ្ឋបាលគ្រប់គ្រងផ្នែកចំណីអាហារនិងឱសថ (FDA) ៖** យើងអាចនឹងបង្ហាញព័ត៌មានផ្នែកសុខភាពរបសអ្នកជូនទៅដល់ “FDA” អំពីប្រតិកម្មទាក់ទងនឹងអាហារ អាហារបំប៉ន ផលិតផល និងការខូចខាតផលិតផល ឬព័ត៌មានតាមដានផ្នែកទីផ្សារដើម្បីអោយមានការចេញផ្សាយ ការកែសំរួល ឬការប្រើផលិតផលជំនួស។
- **ប្រាក់សងជំងឺចិត្តបុគ្គលិក៖** យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពក្នុងកម្រិតដែលអាចអនុញ្ញាតបាន និងក្នុងកម្រិតចាំបាច់ ដើម្បីអនុវត្តតាមច្បាប់ទាក់ទងនឹងប្រាក់ សងជំងឺចិត្តបុគ្គលិក ឬកម្មវិធីស្រដៀងគ្នាផ្សេងទៀតដែលកំណត់ដោយច្បាប់។
- **ហានិភ័យចំពោះសុខភាពសាធារណៈ៖** យើងអាចនឹងចែករំលែកព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកសម្រាប់សកម្មភាពសុខភាពសាធារណៈដូចជា សកម្មភាពក្នុងគោលបំណងការពារ ឬគ្រប់គ្រងជំងឺ ការពារគ្រោះថ្នាក់ ឬពិការភាព និងការរាយការណ៍អំពីការធ្វើបាប ឬការមិនយកចិត្តទុកដាក់របស់កុមារ មនុស្សចាស់ និងសមាជិកគ្រួសារក្នុងបន្ទុក។
- **មណ្ឌលអប់រំកែប្រែ៖** ប្រសិនបើអ្នកស្ថិតនៅក្នុងមជ្ឈមណ្ឌលអប់រំកែប្រែ យើងអាចផ្តល់ព័ត៌មានដល់មណ្ឌល ឬភ្នាក់ងារកាន់កិច្ចការរបស់អ្នក ពីព័ត៌មានសុខភាពដែលចាំបាច់សម្រាប់ថែរក្សាសុខភាពរបស់អ្នក រួមទាំងសុខភាព និងសុវត្ថិភាពរបស់បុគ្គលផ្សេងទៀត។
- **អ្នកអនុវត្តច្បាប់៖** យើងអាចបញ្ចេញព័ត៌មានសុខភាពរបស់អ្នក ទៅដល់អ្នកអនុវត្តច្បាប់ ស្របទៅតាមតម្រូវការនៃច្បាប់ ឬឆ្លើយតបទៅនឹងដីកាដែលមានសុពលភាព។

**សិទ្ធិចំពោះព័ត៌មានសុខភាពរបស់អ្នក**

ទោះបីកំណត់ត្រាព័ត៌មានសុខភាពរបស់អ្នកស្ថិតនៅជាមួយគ្រូពេទ្យ ឬស្ថាប័នដែលរក្សាទុកវាក៏ដោយ ប៉ុន្តែព័ត៌មានទាំងនោះជារបស់អ្នក ។ យោងទៅតាមច្បាប់សហព័ន្ធ អ្នកមានសិទ្ធ ៖

- ស្នើសុំការដាក់កម្រិត លើការប្រើប្រាស់ឬបញ្ចេញព័ត៌មានខ្លះ របស់អ្នក ។
- ស្នើសុំមិនអោយចែករំលែកព័ត៌មានទៅក្រុមហ៊ុនផ្តល់ធានារ៉ាប់រងសុខភាព ប្រសិនបើការព្យាបាលត្រូវបានទូទាត់សព្វគ្រប់រួចហើយ ។
- ទទួលច្បាប់ចំលងរបស់សេចក្តីប្រកាសអំពីការអនុវត្តឯកជនភាព (ការរក្សាភាពសម្ងាត់ ពីព័ត៌មានរបស់អ្នកជំងឺ) នោះពេលអ្នកស្នើសុំ ។
- ពិនិត្យ និងថតចំលងកំណត់ត្រាព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ដោយដាក់ការស្នើសុំទៅមន្ត្រីអនុវត្តឯកជនភាព HIPAA ។ អ្នកអាចត្រូវបង់ប្រាក់បន្តិចបន្តួចក្នុងការទទួលកំណត់ត្រានោះ ។ អ្នកអាចទទួលការឆ្លើយតបរវាងពី 10 ទៅ 30 ថ្ងៃ ហើយយើងនឹងផ្ញើសំបុត្រទៅអ្នកបើការឆ្លើយតបអាចមានការយឺតយ៉ាវ ។ ក្នុងករណីកម្រខ្លះ យើងអាចនឹងបដិសេធការស្នើសុំពិនិត្យ និងថតចំលងកំណត់ត្រាព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ។ ក្នុងករណីនេះ អ្នកនឹងទទួលសំបុត្រពន្យល់ពីហេតុផល និងព័ត៌មានពីការតវ៉ាទៅប្រធានស្ថាប័ន (ឬរដ្ឋមន្ត្រីក្រសួង) សុខាភិបាល និងសេវាកម្មពលរដ្ឋ ប្រសិនបើអ្នកចង់ធ្វើការតវ៉ា ។
- ស្នើសុំការកែប្រែព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក ប្រសិនបើអ្នកគិតថាព័ត៌មានទាំងនោះមិនពិត ឬមានការខ្វះខាត ។ អ្នកអាចធ្វើការស្នើសុំនេះទៅមន្ត្រីអនុវត្តឯកជនភាព HIPAA ។ អ្នកអាចត្រូវបង់ប្រាក់បន្តិចបន្តួចក្នុងការទទួលកំណត់ត្រានោះ ។ អ្នកអាចទទួលការឆ្លើយតបរវាងពី 10 ទៅ 30 ថ្ងៃ ហើយយើងនឹង